# សេចក្ដីបញ្ជាក់

ដោយឃើញថា រឿង "ស្រទបចេក" នេះ មានប្រជាប្រិយភាព នៅក្នុងសន្ដានចិត្តអ្នករៀនសូត្រ និងអ្នកស្រុកខ្មែរគ្រប់ទិសទី ពុទ្ធសាសនបណ្ឌិត្យ ក៏ចាត់ឲ្យចម្លងរឿងនេះពីសាស្ត្រាស្លឹករឹត ហើយបោះពុម្ពឲ្យបានច្រើនក្បាលហើយ ។ ការចម្លងបោះពុម្ពនេះ យើងបានរក្សាទុកនូវសម្ផស្សកាព្យ សំនួនវោហារ និងពាក្យពេចន៍ទាំងស្រុងរបស់អ្នកនិពន្ធដើម ប្រសិនជាមានពាក្យណាគួរសង្ស័យ យើងបានយកសាស្ត្រាជាច្រើនច្បាប់មកផ្ទៀងផ្ទាត់ រកឲ្យទាល់តែឃើញសមហេតុផល ។ យើងនៅប្រែកែខាងអក្ខរាវិរុទ្ធមួយមុខប៉ុណ្ណោះ ដើម្បីតម្រូវទៅតាមវចនានុក្រមសព្វថ្ងៃ ។

ក្នុងការបោះពុម្ពលើកទី ៣ នេះ យើងបានសម្រួលខាងការរៀបបន្ទាត់តាមពាក្យកាព្យ ឲ្យមានលំដាប់ស្រួលងាយក្នុងកិច្ចសិក្សា ដោយមានចុះលេខរៀងនៃគាថាឬឃ្លាល្បះនៃកាព្យ គឺចុះលេខក្នុង ៥ គាថាម្ដង ។

ចំណែកខាងប្រភពដើមឬប្រវត្តិនៃរឿងនេះវិញ យើងក៏ចុះសេចក្ដីស្រាវជ្រាវខ្លះដើម្បីជាជំនួយដល់អ្នកសិក្សាស្រាវជ្រាវទូទៅ តាមការដែលយើងរកឃើញ, មានសេចក្ដីដូចតទៅ ៖

ពាក្យកាព្យរឿងនេះ តាមច្បាប់សាស្ត្រាស្លឹករឹត ដែលមានក្នុង

បណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យ ឃើញដាក់ឈ្មោះថា "រឿងទេវវង្សកុមារ"(១) តែយើងបានឃើញសាស្ត្រខ្លះ នៅតាមវត្តនានាបានដាក់ឈ្មោះរឿងនេះថា "រឿងស្រទបចេក" ។ យើងសន្និដ្ឋានថា ឈ្មោះរឿងទេវវង្សកុមារនោះ គេដាក់តាមនាម ដែលព្រះឥន្ទ្រថ្វាយចំពោះតួអង្គឯកក្នុងរឿងនេះនៅពេលអភិសេកឡើងសោយរាជ្យ ។ ឯឈ្មោះថារឿងស្រទបចេកនេះ គេយកតាមប្រវត្តិដែលតួអង្គឯករឿងនេះផ្លាស់សំពត់អាវរបស់ខ្លួន យកទៅស្រោបមាតាដាក់ក្ដារមឈូស ហើយយកស្រទបចេកមកស្លៀកធ្វើសម្លៀកបំពាក់ នៅបាំងសព ។ បណ្ដាឈ្មោះទាំង ២ នេះ ឈ្មោះថារឿងស្រទបចេក អ្នកស្រុកស្គាល់ច្រើនជាង ។

យើងបានដាក់ឈ្មោះរឿងនេះ ថា "រឿងស្រទបចេក" ឲ្យស្របតាមឈ្មោះដែលអ្នកស្រុកស្គាល់ច្រើនផង តាមឈ្មោះដែលមានក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំជាតិផង ។

ក្នុងការស្ដែងរឿងនេះ កវីនិពន្ធបានបញ្ជាក់ថា លោកនិពន្ធតាមដែលបានស្ដាប់អំពីបណ្ឌិតមហា ម៉ៅ ជាអ្នកចេះអក្សរប្រែ សំដែងប្រាប់ថា មានក្នុងគម្ពីរទុកនិបាត, តែយើងបានស្រាវជ្រាវរកមើលក្នុងអដ្ឋកថាជាតក

១-បើសរសេរថា "រឿងទេវវង្ស" ឬ "រឿងទេពវង្ស" ប្រែថា វង្សរបស់ទេវតាវិញ មានន័យល្អជាង ព្រោះក្នុងផ្ទៃរឿងនេះថា ព្រះឥន្ទ្រដែលជាអតីតបិតារបស់កុមារនោះ បានមកជួយឧបត្ថម្ភកុមារ ឲ្យបានដល់បានអភិសេកសោយរាជ្យ ថ្វាយព្រះនាមថាព្រះបាទទេវវង្ស ។



ឈ្មោះទុកនិបាតទៅ មិនឃើញរឿងនេះសោះ ទាំងបញ្ញាសជាតក ក៏មិនឃើញដែរ តែយើងសន្និដ្ឋានថា ដែលថាមានក្នុងទុកនិបាតនោះ ប្រហែលជាទុកនិបាតឯណាពិសេសក្រៅពីអដ្ឋកថាជាតក និងបញ្ញាសជាតកទៅទៀតក៏មិនដឹង ដែលយើងកំពុងតែស្រាវជ្រាវរកតទៅទៀតនៅឡើយ ។

អ្នកនិពន្ធរឿងនេះ ឈ្មោះ ជិង ស្រុកកំណើតនៅភូមិកំព្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ជាបុត្រនាង មុំ និងចៅពញាកត្ដិកាសា យស ជាមន្ត្រីកផការ ឬ ជាអាជ្ញាហ្លួនទទួលភារៈខាងការចែកមតិក ។ កាលពីកុមារមាតាបិតាបានឲ្យបួសរៀន នៅវត្តកោះឫស្សីស្រុក ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ លុះសឹកមកក៏បានមកនៅក្រុងភ្នំពេញ សុំចូលបំរើគាល់ហ្លួនព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម ។ ដោយព្រះអង្គទ្រង់យល់ថាបុរសនេះជាអ្នកចេះកិច្ចការជាងឆ្លាក់ក្បាច់ ព្រះអង្គក៏ទ្រង់ត្រាស់ឲ្យចូលធ្វើការក្នុងក្រុមជាងស្ពាន់ក្រាប់ ។

លោកបាននិពន្ធរឿងនេះ នៅក្នុង ព.ស. ២៤៣១ គ.ស. ១៨៨៩ ។

ភ្នំពេញថ្ងៃ ២៧ កុម្ភៈ ១៩៦៧

ពុទ្ធសាសនបណ្ឌិត្យ

# រឿងចៅស្រទបចេក

## បទកាកគតិ

១- នេះបទកាកកាព្យ ខ្ញុំនិពន្ធក្រាប ក្រញាំក្រោមបាទា
ហត្ថាដោយដៃ ដាក់ផ្ដិតដល់ធរា លើសិរសា
បង្គំគិតដល់ ។

ព្រះអង្គមានបុណ្យ ទ្រង់នូវព្រះគុណ ប្រាកដថ្កើងថ្កល់
ជាតិជាគ្រូគ្រប់ សាយសព្វសាកល ទីនរកអ្នកផ្ដល់
ផ្លូវផ្ដើមតាំបាន ។

បង្គំព្រះធម៌ ប្រធានធំក្រៃ ក្រៃពន់ប្រមាណ
ប្រមើលមើលមក គន់រកក្នុងប្រាណ ប្រដូចកលបាន
ផុះហើយហោះផ្សែង ។

បង្គំព្រះសង្ឃ បច្ចេកពុទ្ធពង្ស ពោធិច្បាស់ចង
សាវកអនេក ឯងឯកឥតហ្មង ឥតមោះមានខ្ទង
ទ្រង់សីលសិក្ខា ។

៤- បង្គំពោធិ៍ សត្វសាងបារមី តាមព្រះស្រីអារ្យ-
មេត្រីត្រើសទ្រង់ នូវអង្គព្រះមហា ឫសីសីលា
ឥន្ទព្រហ្មតាំងឲ្យ ។

ទេវបុត្តទេវតា តាំងទសទិសា សោឲ្យសសួគ៌ធាយ

ព្រះសូរ្យចន្ទ្រា ភពករភាយ ឥស្សរាភរណ៍
រុងរឿងសោភា ។

តាំងព្រះធរណី គង្គាអគ្គី គុណគាប់ទេវតា
ព្រះកាយព្រះវៃ- ស្រពណ៌ថ្លៃសោ ភិសេសសុភោ
សត្វសព្វមនុស្ស ។

ខ្ញុំបន្ទំគុណ គ្រប់ប្រសើរលន់ ប្រជាំអក្ខរ
បំបួសបង្រៀន ប្រាប់ប្រៀនធម៌អាថ៌ បណ្ឌិតា
មាតារៀមច្បង ។

ខ្ញុំបន្ទំគត ប្រាថ្នាសូមបុណ្យ សូមរុងរឿងផង
សូមសុខសួស្តី បារមីជាច្បង ជៀងជួយចម្លង
ផុតទុក្ខភយា ។

១០– សូមឈ្មោះលោកតា ទោសាមោហា កំណាញ់ឫស្យា
បរលោកនាយក្តី លោកិយនេះណា សូមអស់ទៅគា
ចំរើនសួស្តី ។

រីខ្ញុំបាទជាក់ ជាតិជាកូនអ្នក ទៅពញាតក្តី–
ភាសាចំពោះ មានយសស័ក្តិប- ពានពិតស្រដី
ហានមុខមតិក ។

ទៅមុខឯទៀត មានប្រើនស៊ូខស្ទៀត ពិតពុំកុហក



នាមដើមក្លួ យ(១) ឥតជើងឥតស្លក់ ក្អកក្អែកក្អក់
តែក្លួខេ ។

ក្លួ ស ប្រកប ប្រាកដរបប ប្រមូលអក្ខរ
ឈ្មោះនេះប្រពៃ ថ្លាថ្លៃលើសគេ មនុស្សសត្វសិងតែ
ប្រាថ្នាចង់បាន ។

រីនាមអ្នកមេ អក្សរ ម(២) ប្រែ សម្រាប់ទៅថ្កាន
រៀបតាមចំនង រំលងបីជាង ដល់ឈ្មោះអ្នកមាន
គុណគាប់ប្រពៃ ។

១៥– ក្លួម៉ាំនបិតានៅ ស្រុកស្រុកកំព្រៅ ក្នុងខណ្ឌខេត្តស៊ី-
សុន្ទរកណ្ដាល គ្រាកាលអស់ក្តី បណ្ដាប្រុសស្រី
នៅសុខក្សេមក្សាន្ត ។

ឯនាមខ្ញុំណា មាតាបិតា អនុញ្ញាតប្រោសប្រាណ
ឲ្យមានឈ្មោះខ្ញុំ ផ្សែផ្សំជោយដាន ឈ្មោះញាតិសន្តាន
ពង្សាវតារ ។

លោកគិតយោនយក តួអក្សរ ជ(៣) បំបែកអន្តរ

---

១ បិតាឈ្មោះ [illegible] ជាចៅពញា [illegible] – ២– មាតាឈ្មោះ ម៉ី នៅភូមិ [illegible] ស្រុក [illegible] ៣– [illegible]

ពោលពីរគុំកប់ បន្ទាប់នោះណា យកត្នូរ ង ថា
ប្រកបឈ្មោះខ្ញុំ ។

រៀមមេត្តា អាសូរករុណា ចិញ្ចឹមលុះធំ
បានធ្លាប់ថ្វាយថ្លៃ ហើយនៃអ្នកពុំ ឲ្យនៅលងលំ
ផ្ដេសផ្ដាសឡើយណា ។

ទើបនាំខ្ញុំបាទ លីលាលះលាភ ពីផ្ទះមាតា
មកឲ្យបួសនៅ នាស្រុកចំការ វត្តនោះឈ្មោះថា
កោះឫស្សីស្រុក ។

២០– ខ្ញុំបានបួសនៅ យូរបន្តិចទៅ លោកគអផ្សុក
រំជួលក្នុងប្រាណ រំខានចិត្ត ខឹងនៅពុំសុខ
សឹកចេញមកថ្វាត់ ។

ចរចូលបន្ទំ ថ្វាយខ្លួនជាខ្ញុំ ជាមហាតលិកក្សត្រ
មកុដកម្ពុជា បុប្ផាទាំងគាត សព្វសាសន៍សឹងកាត់
មូលមកបន្ទំ ។

ព្រះបរមនាថ ទ្រង់នាមព្រះបាទ សម្ដេចព្រះឧភេក្ដម
បរមកមា ទេពសួស្ដិសម ចក្រពត្តិជាអ-
ម្ចាស់ផែនភា ។

ព្រះនាកយណ៍ធិបតីន្ទ ជាមហោមហិន្ទ មហោឡារ



មហាទិព្វឫក្ស ធម្មិកមុហា បរមកជា-
ធិរាជធិបតី ។

ជាម្ចាស់ជីវិត បរមបពិត្រ ព្រះចៅចក្រ
ព្រះមកុដបមពង្ស ស្ដេចទ្រង់ប្រោសបទី នូវខ្ញុំនេះនៃ
ថាចេះការគាប់ ។

២៧– ទ្រង់មានឧត្ដារ ទីងព្រះកាញ្ចនា ជាជាងស្ដាខក្រាប់
ឲ្យយកខ្ញុំទៅ ប្រជៅការគាប់ ធ្វើជាងសម្រាប់
ប្រដាប់រាជការ ។

ការកាលនៅថ្ងៃ បន្ទំបនប្រពៃ ជប់កើតមាសា
ផល្គុនគាប់គួរ រដូវហេមន្ត ជួបបណ្ឌិតមហា
មៅមានយោបល់ ។

ចេះអគ្គប្រប្រាយ ប្រាជ្ញប្រុះក្រោនក្រោយ ក្រោនក្រៃខ្ញុំឥតសល់
បរបែបក្លែបក្លាយ ឥតក្ដាយឥតខ្វល់ ទេរិះរៀនរល់
ទីរៀនរៀបរាប់ ។

វេលានោះណា អ្នកបណ្ឌិតមហា សិរីផែនធម៌គាប់
អស្ចារ្យក្រេងពាល ត្រកាលចូលស្ដាប់ បង់ជីងចេះច្បាប់
ទៀនទុកជាខ្នាត ។

គាត់សរីផែនឈ្មោះ ក្នុងគម្ពីរឈ្មោះ ហៅទុកឧបាត

ផងណាផងណាល    កាលព្រះមុនីនាថ    អន្ទោលយកជាតិ
ក្នុងសង្សារវដ្ដ ។

៣០– នៅក្នុងសាសនា    សម្ដេចព្រះមហា    ពន្ទុកផងស្រី
ទ្រង់នាមប្រាកដ    ព្រះពុទ្ធវិបស្សី    សេពសាងបារមី
នាំសត្វសំខេយ្យ ។

នាមព្រះទេវវង្ស    កុមារព្រើសទ្រង់    ព្រះបារមីតា
ខ្ញុំពុំផុះ    ស្រណោះណាស់ណា    នឹកក្នុងចិន្ដា
ចង់ចម្លងទុក ។

ឲ្យអស់មហាផល    មៀនមើលយកបុណ្យ    យកផលទៅមុខ
សួរកច្បាប់គ្មាន    ក្នុងប្រាណវិតក្ក    ពុំសានក្ដីសុខ
ពុំសូវសប្បាយ ។

រិះរកច្បាប់គ្មាន    ចាំតែនិទាន    នៅក្នុងអត្ថកាយ
អន្ទុយរិះគិត    ផ្អែតផ្អិតសាយ    រសល់ឆ្ងល់ឆ្ងាយ
ស្ដាយរឿងនេះឯង ។

ចង់រៀនរើស    ររកចំណេះ    ចំណាំនឹងថែង
ពុំបានបទខ្ទៅ    នោតនៅល្បិចល្បួន    ល្បិតល្បួនដំណែន
ពាក្យពេចន៍ភក់ជ្រៅ ។

៣៩– កុំថេះអន្លៃប្រែ    ទឹងគិតនឹងរែក    នឹងគេចបកទៅ



តែសត្វខ្ទាំង    ចិត្តតាំងទុកទៅ    មិនឲ្យអសៅ
អសារសូន្យសោះ ។

ខ្ញុំគិតលើកលែ    គន់គិតរវៃ    គគេះគគោះ
តាំងចញ់តាំងតាល់    ធ្លាយធ្លល់ផើះផោះ    ដោយចិត្តស្ម័គ្រស្មោះ
ពុំគិតព្រួយប្រាណ ។

តែងៗឈប់ៗ    ពេលថ្ងៃរះឈប់    រកចូលចាន
ក្សិតខ្ទួនកំសត់    ទុគិតស្រេកឃ្លាន    កិតភ័យក្រែងមាន
ក្រអាយទៅមុខ ។

មួយក្រែងលោកណា    មែនមានប្រាជ្ញា    សូមជួយទំនុក
បំរុងទៀតទៅ    ខុសត្រូវតែងទុក    កុំគិតកកុក
កែជាអាយនាយ ។

កុំស៊ើបចំអក    ចំអន់ឡប់ឡក    ក្រែងកើតកម្មកាយ
ពាក្យត្រង់ណាខុស    លុបចុះកុំស្ដាយ    ជ្រៀតឡើងនាយកាយ
បុណ្យបានដូចគ្នា ។

៤០– តាំងបាត់ថែងចង    លៃលើកល្បើកល្បង    រឿងព្រះពុទ្ធា
ផងមួយកើតគូរ    ត្រូវថ្ងៃអង្គារ    ផល្គុនមាសា
រដូវហេមន្ត ។

ឆ្នាំជូតជៀងជាក់    សំរិទ្ធិស័ក    ពុទ្ធសករាជគ្រាន

កន្ទេលពោះស្មោះ   ចំពោះពីរពាន់   ខឹងមួនរយស្បាន់(១)

សាមសិបមួយ(២)ផង ។

ទែកន្ទេលបាន   ដប់ខែមិនខាន   ថ្ងៃសោកកន្ទេល

ទៅបានមេត្ដប្អូន   គ្រប់គ្រាន់ជាម្ដង   នៅឯមុខហោង

ពីរពាន់វស្សា ។

ប្រាំរយឆ្នាំ   ហុកសិបប្រាំបី   វេរសោកណា

សល់ពីរនៅក្រៅ   ដោយទូរះបស្ដា   អធិកមាសា

ថ្ងៃសោកខានប្អូន ។

ចុកចាំងអតីត   អនាគតគិត   បច្ចុប្បន្នមិនមួន

សិរីជួនចប់   គ្រប់គ្រប់គ្រាន់ជួន   ប្រាកដថែជួន

ប្រាំពាន់វស្សា ។

៤៩– ខ្ញុំនឹងសរសេរ   ដំណាលដំណើរ   ទំនងគាថា

កាលពីព្រះអង្គ   ស្ដេចគង់គម្នា   ស្ថិតក្នុងវិហារ

ព្រះជេតពន ។

ជួបជុំអរហត្ត   អរហន្តបរិស័ទ   ទេវតាមហាជន

---

១ សាស្ត្រាស្លឹករឹតរបស់ពុទ្ធសាសនបណ្ឌិត្យ ត្រង់នេះជា មួយរយ តែយើងកែជា មួនរយ វិញតម្រូវតាមសេចក្ដីពិតដូចមានក្នុងពិធីប្រាប់សករាជនៅទីនេះស្រាប់ ។ ២– ព.ស. ២៤៣១ គ.ស. ១៨៨៩



ចូលថ្វាយវន្ទា   ជុំជានិរន្តរ៍   ស្ដាប់ព្រះមានបុណ្យ

ស្ដែងស្ដេចទេសនា ។

ពន្លកជិនស្រី   ជាដើមគតក្រៃ   ទ្រង់ព្រះមេត្តា

ឲ្យគក់ពាន   ប្រោសប្រាណករុណា   យក្ខគ្រុឌនាគា

មនុស្សសត្វប្រុសស្រី ។

ទ្រង់ត្រាស់សំដែង   សណ្ដាប់តារតែង   កាលយកជាតិ

ក្នុងសង្សារវដ្ដ   ផ្ដាក់ឃ្នាតខ្មី   សេពសាងបារមី

ដឹកនាំសត្វផង ។

បើកបន្ទូលថា   កាលក្នុងសាសនា   ព្រះពុទ្ធមួយហោង

នាមវិបស្សី   បារមីជាច្បង   នឹងនាំចម្លង

សត្វសែនអសង្ខេយ្យា ។

៥០– កក្កុស័យកាលនោះ   មានសេដ្ឋីឈ្មោះ   ហៅធនមហា-

សេដ្ឋីធំស្តុក   នៅស្រុកមួយណា   សន្មតហៅថា

និគមគ្រាមខ្មី ។

នៅក្នុងនគរ   មួយនោះនាមា   ហង្សាវតី

ធម្មាជា   ក្សត្រាធិបតី   គ្រប់គ្រងបុរី

ជាទីកំណត់ ។

សេដ្ឋីនោះណា   មិនមានករិយា   ឈ្មោះកុំប្រាកដ

ក្នុងបាលីគ្នាខ    ពុំបានសន្ទក    សេដ្ឋីប្រតិព័ទ្ធ
ស្រឡាញ់ពន់ពេក ។

រីនាងនោះនៃ    រូបឆោមប្រពៃ    ចំលៀវចម្លែក
កបខ្លួនលក្ខណ៍    ឥតតាក់ទើសក្អែក    តាត់ទុកជាឯក
ដោយខ្សែកមួយបាន ។

ខ្ញុំកំដរផង    មាសប្រាក់កែវកង    ពិទូរ្យសុប្បការ
អនេកអនន្ត    ច្រើនពន់ប្រមាណ    គ្រឿងគ្រឹះគ្រែយាន
សំពត់អាវស្បៃ ។

៥៩– កន្តោធុនមាស    លុយកាក់ប្រាក់កាស    គរទុកច្រើនក្រៃ
ប៉ែតសិបកោដិឃ្លាំង    ពេញតាំងអស់ៗ    ផ្ទះថ្មវិស័យ
ដំណាក់ស្តេចស្តែង ។

ក្របីគោសេះ    ដំរីរទេះ    ទូកតូចធំធេង
តែសាយតែហ៊ា    មើលទៅចំពែង    ចំឡែកគួរស្ញែង
គួរស្ងើចស្ញុលស្ញប់ ។

តែណែរទូកដ    កំពេលល្អ ៗ    ដាក់ជើងចែវចប់
ឃ្លានកុកកណ្ដឹង    ទ្រហឹងឮសព្ទ    មានខ្ទង់ជាតគ្រប់
កន្ទ្យាក់ ។

សំបាំងសំពៅ    នោះឯងកែងទៅ    ជួញសព្វនគរ



ស្រុកនោះក្សេមក្សាន្ត    ឥតមានភយា    កណ្ដាលជលសា
សិងសុខសប្បាយ ។

សម័យមួយនោះ    មែនមានបុរស    អ្នកនៅស្រុកឆ្ងាយ
ពីស្រុកសេដ្ឋី    នោះនៃចម្ងាយ    ផ្លូវមួយខែថ្ងាយ
ទើបទៅបានដល់ ។

៦០– បុរសនោះមិញ    នានាំទំនិញ    ទៅលក់ច្រើនសល់
ក្នុងស្រុកនិគម    គ្រាមាសាកល    បរិបូណ៌បានដល់
សេដ្ឋីទូហារ ។

ឡើងទៅលើផ្ទះ    ក្រញ្ញក្រាបសំពះ    សេដ្ឋីនោះណា
សំណោះស្រោកស្រួល    ទទួលចរចា    សួរសព្វប្រការ
ទៅវិញទៅមក ។

បុរសនោះយល់    សេដ្ឋីនិម៉ល    ឥតបុត្រពន្លក
មានតែទ្រព្យធន    ច្រើនពន់ទីងរក    ទីងរះកប់យក
ពុំអស់ឡើយណា ។

ហើយបុរសនោះ    ទូនកាយក្រាបចុះ    និយាយអួតថា
លោកម្ចាស់មានទ្រព្យ    ប្រជាប់ប្រជា    តែគ្មានបុត្រា
បុត្រីទាំងឡាយ ។

នឹងឲ្យស្នងគន្ធ    កត្វូជតពង្ស    ឲ្យយើងយូរឆ្ងាយ

សេដ្ឋីឮហោះ ថានេះអ្នកកាយ ខ្ញុំគាល់ខ្ញុំណាយ
សោយចិត្តគិត ។

៦៩– មិនដឹងធ្វើម្ដេច សព្វប្រការកិច្ច ចេញគាល់គំនិត
បំណាច់អ្នកថា មេត្តាពិនិត្យ ក្រែងបេះដឹងជិត
ដោយហេតុអ្វី ៗ ។

បុរសនោះឆ្លើយ ថាម្ចាស់ខ្ញុំអើយ ខ្ញុំដឹងសេចក្ដី
តែថាឆ្ងាយសល់ គិតយល់ក្រក្រ ក្រែងលោកសេដ្ឋី
ទៅមិនដល់ឡើយ ។

ឯស្រុកខ្ញុំកូវ មានវត្តមួយនៅ នាព្រៃធំហើយ
អំពីបុកណ បុណ្យមានជាត្រើយ វត្តនោះលោកអើយ
បញ្ចុះព្រះធាតុ ។

ព្រះបច្ចេកពោ– ធិសត្វសេដ្ឋា ចូកដល់ឃាត
បន់ស្ងំគាប់ទុក ចំហុតជាក់ជាត បុណ្យព្រះមុនីនាថ
ជឿនជួយជាក់ស្ដែង ។

សេដ្ឋីបានស្ដាប់ បុរសប្រាយប្រាប់ អរេតថ្លឹងថ្លែង
ហោះអញជួលៈចាំ ទៅនឹងអញឯង ជួបជូនតាក់តែង
បង្ហាញផ្លូវព្រៃ ។

៧០– ពីនេះទៅនោះ ឯងជូនទៅចុះ អញនឹងឲ្យថ្លៃ



បើបានដល់ហើយ ហៅអើយតាប៉ៃ អញឲ្យមួយថ្លៃ
មួយជញ្ជីងប្រាក់ ។

បុរសស្ដាប់ហើយ ត្រេកអរផុតស្បើយ ព្រមល្មមកក់ទាក់
ទទួលពាក្យពេចន៍ ស្រាប់ស្រេចឥតអាក់ លាថយជំណាក់
នៅមួយអន្លើ ។

សេដ្ឋីពុលធ្ងន់ ចរចូលទៅក្នុង ថាថ្លៃប្រាប់ប្រើ
តាសឡេទៅ ហៅនាងប្រសើរ មេនោះលលើ
លលូនចូលទៅ ។

ក្រញ៉ាំក្រាបសំពះ ហើយអ្នកជាម្ចាស់ លោកប្រុសឡើងហៅ
ប្រពន្ធឮហោះ ស្ទាស្ទុះទៅកៅ ចរចេញមកក្រៅ
ចូលវៀនស្វាមី ។

ដល់ហើយសឡឹម ចរចូលទន្ទឹម អង្គុយខាងប្ដី
សំពះសួរថា អ្នកហៅខ្ញុំថ្វី ក្បិណានោះសេដ្ឋី
ប្រាយប្រាប់ទៅថា ។

៧៩– នួនល្អងបងអើយ ថ្ងៃនេះឯងហើយ មានអ្នកមួយណា
សេដ្ឋីប្រាយប្រាប់ រៀបរាប់កាថា ដូចពាក្យបុរសថា
និយាយពីខ្លួន ។

ហើយប្រាប់ទៀតថា ឥឡូវនេះណា ជួលគេហើយស្ងួន

ជូនទៅប្រាកដ ដល់វត្តមែនមួន ទីដបានថែជូន

ធ្វើបុណ្យថែបន់ ។

សូមសុំកូនទៅ ក្រែងបានដូចឪ បំណាប់បំណន់

រៀបនូវប្រដាប់ ឲ្យជាប់ស្រាកន់ គិតឲ្យក្រែលគ្រាន់

កុំឲ្យមានខ្វះ ។

នាងទេវីស្តាប់ ស្វាមីប្រាយប្រាប់ ជូរធ្លោះអរណាស់

ហើយនាងលុតលា មិម្ចារហ័ស រៀបនូវគោផ្សត់ស្តុ

ស្បៀងរៀងខែផង ។

ហៅខ្ញុំកំដរ មីរមកគុះករ មូលមកហើយហាង

រៀបចំស្រេចស្រាប់ ប្រដាប់ផ្គួង សព្វគ្រប់ឥតបាង

ឥតមានខ្វះខ្វី ។

៨១– វៃអប៉ិតាសា រៀបចំគជា សំរាប់សេដ្ឋី

កូនខ្ញុំផុខប្អូន ហំមួនពិសី ពិះបរសឥតរ៉

ឥតបើចមា ។

ខ្វះរៀបទេះ ខ្វះគោតរៀបសេះ ចងរានថ្ងៃថ្វា

រិតអុកវិតថន(១) ខ្សែហោងខ្សែហោ ថែរណ្ណាខៈចន៎ា

ក្រឡាបគ្រន្ត ។

១ ពាក្យសៀម អុក ត្រុត. ចង ពោះ រិតអុក ខ្សែក្រូតំ រឹតចង ខ្សែតែពោះ ។



រៀបស្រេចរបៀបណា ពិតពុំផ្សេងផ្សារ សេដ្ឋីពុំលន់

ចូលទៅក្នុងផ្ទះ ជំរះអស់អន្ត ទឹកអប់ដុំហុង

ក្លិនសុគន្ធា ។

លាបប្រេងប្រស់ម្សៅ ស្លៀកសំពត់អាវ ហូលព្រែផា ។

ផាហ៊ុំបិនទៅ ប៉ាក់ឡើមាលា ទំមរាត់ពេជ្រពណ៌

ហូលវត្តថ្ងៃ ។

មួកមាសក្បូរក្បាច់ ដាក់ត្បូងរលេច ភ្ញីផ្ទុកវិស័យ

ចិញ្ចៀនវែនលឿង រុងរឿងល្អក្រៃ ចាំពេជ្រប្រពៃ

ពេកពិតជាម្ដង ។

៨៤– ល្អល្អះពិសី ប្រពន្ធនិងប្ដី សមគ្នាឥតហ្មង

រៀបខ្លួនស្រាប់ស្រេច ដើរក្រោចក្រសង ចាកចេញចរផ្គង

ឡើងលើគជា ។

ផ្ដាំខ្ញុំប៉ុន្មាន អម្បាលដែលមាន ឲ្យចាំគ្រឹហា

ប្រយោជន៍ប្រយ័ត្ន កុំអាត់(២)លំលា ទៅណាមកណា

ចោលផ្ទះសម្បែង ។

បើមានព្យុះខ្យល់ បក់បោកមកដល់ ប្រយ័ត្នភ្លើងផ្សែង

កុំឈ្លោះប្រកែក ដាំដកគ្នាឯង ប្រយ័ត្នប្រយែង

២. ពាក្យបុរាណ កុំអាត់ កុំអាក់ខាន ។

ណាំអស់អាក់ ។
ផ្កាស្រេចពេញស្មោះ ឲ្យទៅបុរស ដែលជួលនោះណា
ជាមគ្គុទ្ទេសក៍ វិសេសសោះសា ជិះស្រះលីលា
បរមុខសេដ្ឋី ។
ពួកខ្ញុំកំដរ ស្រុះស្រួលគ្រេកអរ ទាំងប្រុសទាំងស្រី
ខ្វះជិះសេះបរ ពេញបណ្ដោតខ្ញុំ ហែមុខសេដ្ឋី
ប្រើចក្រែកគាន់គាប់ ។
៤០– ខ្វះសោតវេះវេះ ឡើងជិះរទេះ បរបោលប្រញាប់
ប្រញាយហោហា ខ្វះខ្វាដើរគាប់ សន្ធឹកសូរស័ព្ទ
ដូចព្យុះព្យោមា ។
លន់លុះសុរិយេ សៀលជ្រៀនជ្រេ ដល់កន្លែងអង្គា
មៀនមើលព្រៃព្រឹក្ស សន្ធឹកផ្កា ផុះផោយជួរជារ
រវៀបរៀងកាយ ។
ជ្រុនជ្រោយប្រកន្ធ ជ្រោះជ្រុនធារធំ ធំធេងឆ្ងាយ
ថ្មជាថ្មផុះ ខ្ពង់ខ្ពស់យល់ឆ្ងាយ សព្វសត្វប្រញាយ
ហិចហើរតាមផ្លូ ។

## បទភុជង្គលីលា

១– បទបែកតិកបងជា ភុជង្គលីលា លៃលើកពីកាល ។



សេដ្ឋីពិសីពិសាល ពិសេសត្រកាល នាំបរិវារផង ។
លីលាយាត្រាដោយផង ព្រៃព្រឹក្សព្រលង ប្រកប្រៀតបញ្ចា ។
សេដ្ឋីស្រដីទៅថា រុំយកអស់អាក់ ឈប់នៅនេះហើយ ។
៤– សម្រាកសម្រាន្តជាត្រើយ រួតប៉ុក្មេងអើយ ទីនកាលទៅណា ។
ហើយឈប់ក្រោមម្លប់ព្រឹក្សា បរិភោគអាហារ ហើយដើរលេងលេង។
អញខ្ញុំបន្ដំពប់ទេ រកទីទំនង ទំនួលទីនដាក់ ។
យល់ទួលស្រស់ស្រួលភក់តាត មានម្លប់ត្រជាក់ ត្រជុំចូលឈប់ ។
ដាក់ដល់រួចកល់សព្វគ្រប់ ឆុកស្គុលស្គប់ ហើយមហាសេដ្ឋី ។
១០– នាំអង្គដោយយង់ពិសី នូវខ្ញុំប្រុសស្រី លោតលេងសប្បាយ ។
ពនាព្រឹក្សាទាំងឡាយ លាំងសាកស្វាតស្វាយ គគីរគុយគរ ។
ឃ្មោយហាយុសន្ទាយសន្សើរ សន្សំរស- លួសលោតលាំងជ័យ ។
ស្មាស្មាច់ព្រាលព្រោចព្រៃព្រៃ ប្រេសជួយកាំងរៃ រពកកសាវមាវ ។
ល្វាជីស្រវ៉ាស្រទៀវ កប្បាសក្រចៅ ក្រមួនត្រមែង ។
១៥– ពុទ្រាតាន់តារស្វាស្វែង សោមសេសោច់សែង ព្រាលព្រីងព្រាសព្រាំ។
ថ្នាំចថ្លុកចកន្ទុំភ្លុង តាត្រាវត្រសក់ត្រាំ ត្រែងត្រាចត្រៀលស្វា ។
មន្ទ្រុកលម្មើលក្រសា ស្លុកស្លុកខ្នុរខ្នារ ដើមចន្ទមូលី ។
ចំបក់កន្ទួតភ្នួ ក្រូយើងគគីរ មហាហង្សយុក្កា ។
សេដ្ឋីស្រដីទៅថា ម្ដូចអើយមើលផ្កា ចំប៉ីកោយរក ៕

នាងឆ្លើយអ្នកអើយរបេក ផ្កាសស្រស់ពេក រលោងលេចឡើង ។
ចម្ប៉ាកណិការកែវមៀង ដកម៉ៃស្បរឿង រំដួលរំដេញ ។
ម្លិះលាលេចផ្កាពាសពេញ អ្នកប្រុសសំឡាញ់ លំអោញមើលទៅ ។
ច្ចថាំក្រពាលពៅ ស្រីស្រស់ស្រនោ ស្រងើមើលមក ។
មើលផ្កាក្រថុកក្របក គង់ក្ដួចពន្លក ប្អូនអើយមើលមៀង ។
កុលាបដាបពាយរៀង ម្លិះរួតផុះបៀង ផុះបៀតខ្ចីងគ្នា ។
ស្រស់ស្រីទេវីឆ្លើយថា អញ្ចនកណិការ អ្នកអើយមើលចុះ ។
មើលផ្កាក្តាំងនារីកស្រុះ រីកស្រួលឥតខុស ឥតខ្ចបមែកណា ។
សាវ៉ៃយុគយីថាផ្កាច្បា ប្រុសអើយមើលក៏ មើលផ្កាមហាហង្ស ។
ម្ហាលតិខ្ទួនស្រីប្រយន្ត ផ្កាក្រអូបហួង់ នៃប្អូនមាសមើល ។
អស់ស្រីនាសិងងើល ស្អុស្អុះផ្ដើល ប្រាប្រៀតចូលបេះ ។
ខ្លះឡើងខ្លះលោតប្រលេះ ប្រលែងលូកកេះ លូកតាវថ្ងៃចផ្ងរ ។
ខ្លះផ្កាឧបេះបានអីងអរ បន្លូតហើយចរ ចូលជូនសេដ្ឋី ។
ខ្លះបេះប្រលេះមាលតី បានហើយឃ្មាតខ្លី ជូននាងទេវី ។
មើលសត្វប្រភក់រកស៊ី គៀងគូឈ្មោលញី ហិចហើរទៅមក ។
សត្វក្ដុមហើរទំដើមឆ្នក ពញាក់ហើរជ្រក ទំដើមពញ្ញា ។
ដៀបចាបចៀនចាបហើរហោ ទៀងទំដើមចារ សំណាក់និគ្យទៅ ។
សារិកាហើរហែហួសទៅ ហិចហក់សំដៅ ទំដើមស្រគំ ។



ទពាក្រយងហើរទំ ទុកក្រូយាសយំ ស្រែករកគូទៅ ។
ចតាកហើរផ្ទាតផ្ទោះទៅ ទំដើមក្រពៅ ចរចារផ្សៀងផ្អូង ។
លលកហើរមកត្រសង ទំដើមលោតលង លេងលើរុក្ខា ។
ក្រសាំងមានចាំងក្រសារ សំណាក់នៅនា ទីទំសម្រាន្ត ។
បេកទេសបោកទុំហើរផ្កាន ទំនៅតាហាន មិនមានភិតភ័យ ។
សត្វខ្វឹងកែងទំដើមឃ្លៃ ដើមកំសត្តិរ ទំយំលលោច ។
សំពារមានចាំងសំពោច យាសយំស្រណោច ស្រនាត់អញ្ញា ។
ម្រឹគតក្រឹកតាមគ្នា ទន្សោងខ្លោងខ្លា រមាសរមាំង ។
ព្រើសព្រាយទន្សាយខ្ទីងក្ទាំង បោលបោះយាងក្ទាំង បំព្រៃកស៊ី ។
សព្វសត្វប្រាក់ឈ្មោលញី ពាសពេញប្រថពី ប្រកិតគណនា ។
ច្រើនក្រៃក្នុងព្រៃព្រឹក្សា ក្រស្គាល់គាថា បក្សនិងម្រឹគ ។
សេដ្ឋីប្រាប់ស្រីរអិក រអែកចុះទឹក ទៅលេងសប្បាយ ។
ស្រះស្រីពីរព្រៅឆ្ងាយ ដេងធំធូលាយ ថ្វសកាបដងផ្កា ។
ត្រីក្រាចហែលហិចឆ្នៀវគ្នា ត្រីព្រួលត្រីប្រា ត្រីប្រាក់ត្រីមាស ។
ហិចហែលអន្ទ្រែលពេញពាស ប្រឡាកប្រឡះ ប្រឡំគ្នា ។
ក្រឹមក្រាញ់រៀលលេញកន្ធរ ផ្អាងផ្អក់កក្ករ ក្ដាំងហាតក្ដាំងយោយ ។
កាហោទះពាសល្ពាយ ត្រីក្រសាត្រីក្រាយ ត្រីក្រំក្អិតក្ពុក ។
ជងខ្លួនប្រកែងអាចម៍កុក កាក្អាញក៏ក្ដុក កំភ្លៀវថ្មារ ។

ត្រីក្អកត្រីខ្វែកត្រីផ្ទា  ត្រីកញ្ជាក់ស្វា  ស្លុញស្លឹកឫស្សី ។
ត្រីឈ្វាតត្រីស្វាតគ្រើ  គល់ភាំងជើរ  កន្ទ្រប់កន្ទ្រន ។
អណ្ដាតឆ្កែឆ្កោកបន្ទន់  កម្ពឹសព្រោនផង  អនេកក្រាស់ក្រៃ ។
ប្រែប ឈែហបហែលប្រៀវប្រែ  អន្ទែលអន្ទៃ  អន្ទាញទៅមក ។
អណ្ដើករើកភ្ញើក  សសៀរសៀតសិក  សើកសម្ដៅ ។
កន្ធាយកាកាយទឹកទៅ  តាល់ទីត្រីបត្រាវ  ការលបលាក់កាយ ។
ពណ៌នាមផ្កាតាំងឡាយ  ពុំសព្វសុសសាយ  រូត ៗ រំលង ។
មើលទឹកពន្លឺកថ្លារង់  មានភ្ញីផលផង  ដាលដុះរៀងរាយ ។
ឈូកសឈូកប្រាលលៀនលាយ  ស្មោស្លួងសាភាយ  កំភីងភ្លួយព័ន្ធ ។
ចង្វុលរត្ថុចង្វុលណែនណាន់  កញ្ចែតវារវល្លិ៍  ត្រកួនត្រកៀត ។
ព្រលិតដុះជិតជ្រែកជ្រៀត  កក់កង់ដុះបៀត  ស្មោមស្វាបប្រោ ។
សេដ្ឋីតាសីតាសា  លេងក្នុងគង្គា  ហិចហែលទៅមក ។
ភ្ញាស់ខៀវកញ្ចៀវបាចបោក  រំពងរលក  រហោចទឹកទៅ ។
អស់ស្រីហិចហែលសំដៅ  ស្ទុះហក់ហែលស្ទៅ  ស្ទុនស្វាញដេញគ្នា ។
ភក្រញ្ញាកបាចសាចគង្គា  សូរស័ព្ទគា ៗ  រលកអន្ទាញ ។
ខ្លះបាននរណាហកអញ  ឃើញខ្ទួលបាញ់  ឲ្យស្វាបារ ។
ខ្លះបាចង់អើយកុំស្តី  ក្រែងអស់បារី  ភាពឲ្យសហាយ ។
ខ្លះសើចសំណើចក្អាកក្អាយ  ហើយបាហានកាយ  មុជទៅអញ្ជាក់ ។



កុំអួតអន់ឆ្អួតឆយរ  ប្រាជ្ញតែផ្ទហរ  ឲ្យតែគេគោត ។
ខ្លះដេរឆ្លាបមោះគេជាត  បន្តិចកំពក  ក្រពើរាំ ។
ខ្លះជាទេហង់កុំចាំ  មាត់ក្រែងរាំតាំ  យកទៅជាម្ហូប ។
សេដ្ឋីពិសីជាច្បង  ឆ្ងួតស្រេចហើយហោង  នាំអស់បរិពារ ។
ឡើងមកផ្លាស់អម្ពរពស្ត្រ  ស្រាបស្រេចហើយណា  វិលត្រុនដាំ ។
បង្គាប់បរិពារពលខ្ញុំ  ចាត់ចែងរៀបចំ  បង់សេះដំរី ។
ផ្ទុកគោផ្ទុកស្បៀងបំណី  ស្រេចមហាសេដ្ឋី  ឡើងគង់គជា ។
ផ្ទះបរចេញចរលីលា  គ្រាច់ក្នុងព្រៃព្រឹក្សា  វែហហបខ្ទាន់ខ្ទាប់ ។
ទៅវលផង្គោលគាន់គាប់  ស្ទួតស្ទួប្រញាប់  ប្រញាយជ្រែកជ្រៀត ។
ជ្រែករជ្រះប្របេះប្រចៀត  ប្រវង់សឹករសៀត  ដំណើរវៃផ្គា ។
កាត់តែងដោយផងមាគ៌ា  ពុលង់យូរហោ  វែមួយកន្លះ ។
តាសាតាសីក្មេងចាស់  សុខសប្បាយណាស់  ឥតមានរោគា ។
បន្តិចលុះលេចអង្គា  ដល់ដែនវិហារ  ហើយដាក់ឈប់ឈរ ។
អញ្ជើញជួបផ្ដុំផល់មក  ជាគ្នារះរក  ធ្វើរោងក្រសាល ។
ជួនមហាសេដ្ឋីត្រកាល  នៅជាកណ្ដាល  នៃពលបរិពារ ។

## បទកាកគតិ

មហាសេដ្ឋី  ពិសេសពិសី  ចរចូលពន្លា
ក្ដុំក្ដម  សមរម្យសោភា  ជួបជុំគ្នា

ក្បែរស្មើវេលា ។

ថ្ងៃនោះឯងនាង សេដ្ឋីពុំបាន ចូលក្នុងវិហារ
រៀបតែសម្រាប់ ប្រដាប់ប្រដា គ្រប់គ្រឿងសក្ការ
បូជាព្រះធាតុ ។

៩៨– ជាធូបាយសីធំ សមសួនសំណុំ កំពស់ខ្ពស់ស្អាត
ហើយលញ់ទៀនធំ សំណុំតាមខ្នាត ប្រវែងជាក់ជាត
ប្រាំពីរចំអាម ។

តែងផ្កាតែងទង់ តែងទង់គ្រឿងរៀបរង់ ពីព្រឹកព្រហាម
នឹងនាំបរិវារ លីលាទៅភ្នម មិនឱ្យរំងាម
ចាំរៀបណេះណោះ ។

ហើយមហាសេដ្ឋី បរិភោគចំណី អាហាររួចចុះ
ចេញចាកគេហរម្យ ហៅខ្ញុំស្រីប្រុស សើចលេងហោះហុះ
ហាសហាយកាន់គ្នា ។

អធ្រាត្រស្រងាត់ ពពាយផាយផាត់ ពពកហើយហា
ហក់ហួសជ្រួសជ្រះ ស្រឡះមេឃា លឿនលេចចន្ទ្រា
ភ្លឺផ្លេកសព្វសាយ ។

ស្រីប្រុសស្រាកស្រួល ស្រាលស្រើបបបួល គ្នាទៀងមើលផ្កាយ
អ្នកខ្លះស្គាល់ហើយ ឆ្ងាស់ឆ្ងើយប្រាប់ប្រាយ ថានក្សត្រផ្កាយ



ក្រពើហើយហាន ។

១០០– អ្នកខ្លះពុំស្គាល់ នៅនឹកពិភាល់ ងើបងើយផ្ទៀងផ្គង
សួរទៅវិញថា ឯណាអ្នកបង អ្នកប្រាប់ខ្ញុំផង
ឱ្យស្គាល់នឹងគេ ។

ខ្លះថាមេខ្លោច គេប្រាប់ចំប៉ោច មើចមិនឮទេ
ខ្លោចមេខ្ទៅល្ងង់ អញចង់តែជេរ លេះគេគមកវេរ
គឺចង់ៗ ។

ថ្ងៃមិនមើលទៅ ផ្កាយរះសន្ធៅ សុភ្នោសន្ទឹង
មិសគ្លៀសាននៃសួន ធំវែងស្លុកស្តឹង សព្វរះបីពុំណឹង
មិនដឹងមើលថែរ ។

លង់លុះជាស់ចំ ព្រះចន្ទចរចំ ជ្រុងព្រះសុមេរុ
តាកទៀងរះ ព្រឹមព្រៀងតាមវៃ កាលនោះវិធ
សេដ្ឋីជាធំ ។

ដឹកដៃភរិយា នាំអស់បរិវារ ចរចូលគេហរម្យ
វិវេកនិទ្រា ហៅគ្នាជួបជុំ រកដេករកជុំ
ផ្ទំចន់ដោយខ្លួន ។

១០៤– រីឯតានេះ បញ្ឈប់ទុកស្វះ ទើបបងចាប់ផ្តួន
កាលនោះមានមហា សេដ្ឋីមួយអួន មានទ្រព្យធនធួន

ឥតឯកណា ។

ឯសេដ្ឋីនោះ　　នៅស្រុកមួយឈ្មោះ　　បច្ចន្តគាម
ស្រុកនោះក្បែរក្បាន្ត　　ផងមានកយា　　រិររកភោគា

ពិតពុំក្រៀ ។

សេដ្ឋីនោះនាម　　សន្នះហៅតាម　　បទបាទបាលី
មានមកបំពោះ　　ឈ្មោះគោតសេដ្ឋី　　តែចិត្តអប្រិយ

លោកលះជំពេកក្រៃ ។

មែនមានករិយា　　រូបនោមលោកា　　សភាពល្អមល្អ
ទ្រទន់ទ្រទេស　　វិសេសថ្លៃថ្លៃ　　កបលគ្នុណប្រពៃ

ពេកពិតជាម្ចាស់ ។

មានខ្ញុំប្រុសស្រី　　គោសេះដំរី　　សំពត់អាវផង
ហូលព្រែព្រំមាស　　ប្រាក់កាសកែវកង　　ខុកខ្ជប់ធំផង

ពាប់ចកច្រើនក្រៃ ។

១១០-ផ្ទះផ្សារច្រើនល្វែង　　ប្រកប្រផ្ទាត់ខ្វែង　　ហៅណាំនមុំខ្ពែង
ផ្ទះបាយខ្ទង់　　ធំល្វឹងគ្រឿងឈើ　　ខ្ពស់ខ្ពើ

ខ្ទើមពាមគ្នា ។

រានហាលហាលចុះ　　ដាំដើមភ្លាំទុក　　ដំរៀបផ្ទះដាំ
ដើរដាំចិញ្ចឹម　　ដាក់របៀនបម្រើ　　ដើរដាំម្ទេះលា



ផ្តុំដើមម្ទេះក ។

ផ្កាច្រើនពាសពេញ　　មានខ្ញុំចូលចេញ　　ចាត់ចែកគ្នាសួរ
ដំណាំឯដី　　មានលម្អិតខ្ពស់　　កន្ទុំស្រល្ងក

ស្រឡះស្រោងស្រាង ។

ដាំដើមផ្លូវស្វា　　ពុទ្រាខ្នុរទា　　មាក់ប្រេងមាក់ប្រាង
ដាំដើមចាន់ចេក　　គ្រប់ចេកក្បែរខាង　　កំពែងសងខាង

សាយសាបបាយអា ។

ដំណាំជាំផ្ទះ　　មានគ្រប់សាយសុស　　បន្លែគ្នាឧក្រ
ក្រោយបង់ថ្ងៃ　　អាស្រ័យបានប－　　រិភោគផលកុះករ

កើតកបតកក់ ។

១១៩－ សេដ្ឋីនោះណា　　មិនមានបុត្រា　　បុត្រីជល់ម្នាក់
ប្តីនិងប្រពន្ធ　　គិតគន់ស្មោះស្ម័គ្រ　　បន់ទៅសំណាក់

នៃវត្តនោះណា ។

នឹងទៅធ្វើបុណ្យ　　រំលឹកព្រះគុណ　　ព្រះបាទមហា
ឧបត្ថកពោធិ　　វរវិសេសថ្លា　　សូមសុំបុត្រា

បុត្រីបានមួយ ។

គ្រាន់បានការទ្យ　　តតួជតពន្ស　　ទៀងទុកជាត្រួយ
ជាខ្ទឹមជាសារ　　ក្បាលប្រាណព្រួយ　　គ្រាន់បានជៀនជួយ

រក្សាសម្បត្តិ ។

សេដ្ឋីគិតស្រេច ព្រាក់ព្រមពាក្យពេចន៍ ហើយហៅបាវថ្នាក់
បាវព្រាយហៅ រត់ទៅតាមគ្នា ក្រញូក្រាបប្រណិប័តន៍
ចនអង្គុយនៅ ។

សេដ្ឋីបង្គាប់ ថាអាឯងឆាប់ ចចុះចេញទៅ
ប្រាប់ក្មេងចងសេះ រទេះគោក្របី ហើយការត់ទៅ
ប្រាប់គាព្រមាក់ ។

១៦០— ឲ្យបាចផើរ បួនផប់ថ្លៃ ចងក្រូបចងណាក់
ផ្គន់ក្ដាប់មុខ ក្រោមកួកនៃងដាក់ ក្រពាត់ទម្លាក់
កល់កន្ទុយក ។

ឲ្យមកជាធាប់ ត្បិតអញប្រញាប់ ចឹងចរលីលា
ទៅធ្វើបុណ្យទាន ឯស្ថានវិហារ កុងព្រៃនាយណា
អស់ការត់ទៅ ។

ចាំបានស្ដែងស្ដាប់ លុតលាប្រញាប់ ស្រួតរូតសំដៅ
ដើរដល់មិនទាន់ បន្ទន់ស្រែកហៅ កាសកាឡៅ
កាបាប់សេះចង ។

ត្បិតលោកចៅហ្វាយ ឲ្យអញជាតាយ អស់តាំងការផង
ការឯងកុំខ្វល់ ប្រហែសឡើយហោង ត្បិតលោកប៉ុនប៉ង



ចឹងទៅធ្វើបុណ្យ ។

ប្រាប់ហើយហួសទៅ ឯកាសឡៅ ភិតភ័យពេកពន់
ចាប់បានបង្ហៀរ សេះសៀរផ្គន់ ពក្រើតប៉ប្រុន
ភ្ជាបមហាសេដ្ឋី ។

១៦៥— ដើរដល់រេងសេះ ប្រាប់គូររទេះ ឲ្យរៀបណាប់ខ្ញី
ក្រដោកបង្ក្រង ផ្ទុំផ្គង់អស់ក្ដី ចងសក់បារី
បន្ទោលចងខ្សែ ។

កណ្ដាលកណ្ដឹង ចឹមប្រោមខ្សែតឹង បង្ក្រឹងបង្ហៀរ
ស្រេររៀបស្រេចស្រាប់ តាប់តាមកែ ស្រាលសឹងគោខ្មៅ
ប្រាំ វិណាន មួយ ចឹម ។

គោខ្វបង់គ្រឿង សេះសរុងរឿង រូបល្អឥតផ្ទឹម
លុតលៀនចង្កុំ លលាំលទ្ទីម លលាមប៉ប្រឹម
ចង្កូតស្ទុះស្ទាត់ ។

តាញនែបង្ហៀរ ហោលហូរសៀបសៀរ ដើងលេចតីមា៖
ញីកញាប់ខ្លាំង ប្រកាន់ប្រាកដ ប្រកបគ្មានហត់
គ្មានហបឡើយណា ។

ឯបាវសេដ្ឋី ដែលប្រើទៅខ្ញី ប្រាប់ពួកគង់សារ
ថាតែការផង អញឯងប្រាប់ការ ឆ្ឡូវលោកមហា

សេដ្ឋីជាធំ ។

១៣០– ទៅធ្វើបុណ្យទាន ឯព្រះវិហារ ក្នុងព្រៃប្រថុំ
ប្រើអញប្រាប់គា ឲ្យគារៀបចំ បង់វ៉ែង
ឲ្យគ្រប់ចំនួន ។

តាំពីបុសបាន ស្រូវរៀបអស់ប្រាណ ឲ្យមេទាំមួយ
ក្នុងធ្វូសប្រហែល ក្រអែសក្រមួន ក្រអឹកគុសខ្លួន
អញមិនដឹងទេ ។

ឯអស់ខ្ញុំម្នាក់ បានស្តាប់ឮជាក់ ជិះចូលរវេ
ស៊ីចុកស្រូវពន់ ដៃកាន់កង្វេរ ក្រោកដើរអន្ទែ
អន្ទោចូលខ្មី ។

ទៅរកអតជា ចូលស្រាយម្ឆ្នា ប្រញឹកប្រញៀ
ខ្នាតញីញាប់ គ្រឡប់លៃខ្ញី ផល់ហើយម្ចី
ចាំចុះបង់គ្រឿង ។

ជិជំនិះ សេដ្ឋីជាន់ជិះ ល្អល្អះរុងរឿង
បង្គួយមុខបួន ទាំមួនថ្កុំថ្កើង រៀបរបេះស្រេចឡើង
ជិះចរចូលទៅ ។

១៣៥– ព្រមពួកបរិវារ អនេកដាសដារ តាំងក្នុងតាំងក្រៅ
មីមកខាងខ្នាប កាន់គាប់ខ្នលខ្មៅ អង្គុយចាំនៅ



មុខផ្ទះសេដ្ឋី ។

ឯនាងករិយា រៀបគ្រឿងបូជា និងគ្រឿងចំណី
ភោជ្យក្សុអាហារ ពីសាពីស៊ី សាច់ជ្រូកសាច់ត្រី
សាច់មាន់សាច់ទា ។

សាច់ក្ដាន់ប្រហួច មានតាំងម្ហូបគ្រប ទឹកខ្ទះយ៉ាំងជា
ទឹកសៀងទឹកតុំ ទឹកត្រាំបេកញ៉ា បន្ទុំបន្តា
បង្ការអត់ឃ្លាន ។

រៀបរួចសព្វគ្រប់ ចូលក្នុងបន្ទប់ ផ្លូតទឹកលាងប្រាណ
ផាត់ម្សៅមៀត លាបលៀតហ្នត់មាន ទឹកអប់កំញាន
ពិដោរសោភី ។

ងូតទឹកស្រេចហើយ ពិតពុំលង់ឡើយ នាងនាថទេវី
លាបប្រេងព្រោះម្សៅ ស្រស់ស្រីសោភី ទើបនាងនារី
ផ្លាស់សំពត់អាវ ។

១៤០– នាងស្លៀកហូលឯក ផ្កាស្រស់ចំឡែក ផាហ៊ុមបាក់ពៅ
ប្រលាក់ជកគាំ សក្តិសមឥតសៅ ពណ៌ស្រស់ក្មិនឆ្អៅ
ខ្ទុំព្រៃបាក់បា៉ ។

ខ្សែខ្លួនខ្សែដៃ ស៊ីងល្អប្រពៃ ដាក់ត្បូងមាសម្ដោរ
សខ្មៅភ្លឺជាក់ ក្នៀលធ្លាក់សណ្ដោ ពរភ្លូតពភ្លា

ពាក្យមយល់យន់ ។

ចិញ្ចៀនក្បូនពេជ្រ មានមកុដលាយលេច រលែងរលង់
រលោងស្ទើរស្រែក ក្ងោកក្រួយទ្រង់ ក្បូរក្បាច់ទងល្ហុង
ល្ហក់ល្ហាវល្ហាសល្ហូន ។

សេដ្ឋីស្រីប្រុស រៀបខ្លួនហើយចុះ ដើរដ៏គយគន់
ដំណើរញៀងញៀង ល្គយល្គងទន់ភ្លន់ នានាំខ្លួនផង
ចរពារយាត្រា ។

ហើយផ្ដែផ្ដាំខ្ញុំ ក្មេងក្មាងចាស់ទុំ ឲ្យចាំគ្រឹហា
កុំឲ្យប្រហែស ខ្វះខ្វាសឡើយណា កុំឲ្យថ្វស់ការណ៍
កើតមានសៅហ្មង ។

៥–ដាស់តឿនគ្នីគ្នា កុំឲ្យនិទ្រា លក់ពេកឡើយណាន
ថ្ងៃយប់កុំដើរ លេលើលេងលង ចាំរក្សាគ្រង
អស់ទាំងទ្រព្យា ។

ផ្តាំហើយសេដ្ឋី ឡើងជិះដំរី បើកបរលីលា
អស់ខ្ញុំស្រីប្រុស ស្រួលស្រះនាំគ្នា ឡើងជិះអស្សពាហ៍
បររត់ចេញទៅ ។

ហែមុខហែក្រោយ រះដាវជ័យ រចល់ខ្ជុលឡៅ
រំពើតរំពង សឹងកងហោហៅ កក្កូរករៅ



ឲ្យជួបជុំគ្នា ។

សៀលមោងច័រ ផុតដែនបុរី បច្ចន្តគ្រាមា
ចូលក្នុងព្រៃភ្នំ ទុគិមអញ្ចា អស់ទាំងមនុស្សា
ត្រេកអរអឹងកង ។

សប្បាយចិត្តថ្លើម ស្រាលស្រើបជ្រួលជ្រើម មើលអស់ឈើផង
ខ្លះផ្កាខ្លះផ្លែ ដូចគេចាប់ចង ច្រើនក្រៃកន្លង
មិនមានខ្វះអ្វី ។

## បទពុំនោល

១–នេះបទពំនោលស្រដី ឯមហាសេដ្ឋី ប្ដីនិងប្រពន្ធលីលា ។
នាំអស់ពួកពលបរិពារ ស្រូតស្រូតមហិមា ហេតុជាអ្នកលោកខ្ពង់ទ្រព្យ ។
បើនឹងទៅណាចង់ឆាប់ ប្រញឹកប្រញាប់ ប្រញាល់ទឹងតាលអាស៊ុ ។
បានមួយហើយចង់បានពីរ សព្វថ្ងៃសព្វ ខឹងរកទំនេរមិនបាន ។
៨–ប្រាប់ខ្ញុំឲ្យទំរេកាន ទំដើរពារពាន ឲ្យបានតាមដល់វិហារ ។
ដាក់ឈប់ពេលយប់និទ្រា ព្រឹកឡើងទិវា លីលាទៅទៀតជាផ្គង ។
ថ្ងៃមិនឲ្យឈប់ឡើយហោង ទំពេកកន្លង យូរលង់រលងវិល ។
អស់មនុស្សស្រីប្រុសនាំគ្នា បោចបេះផលា ស៊ីលេងបណ្តើរតាមផ្លូវ ។
ខ្លះបេះសម៉ស់ម៉ូរ អ្នកខ្លះបេះផ្កូវ ហោះទៅឲ្យកូនស៊ីលេង ។
១០–អ្នកខ្លះលោលោតកញ្ជេង បេះផ្លែមាក់ប្រេង មាក់ប្រាងសងខាងមាត់

ខ្លះបេះប្រលេះពុទ្រា ខ្លះបេះផ្លែល្វា ផ្លែរាយដកពាយពោនម្នាក់ ។
ខ្លះបេះប្រលេះប្រផាក់ ខ្លះបេះពោត ប្រទាក់ប្រទាញទាំងទង ។
ខ្លះបេះឡើងបេះសំរោង ប្រទាញប្រទាន់ ទំនងដំណើរដូចស្វា ។
ខ្លះបេះប្រលេះបុប្ផា សៀតលេងត្រៀងថា រៀបរាយទំនុកទំនើរ ។
ត្រៀងត្រងទំនងអ្នកលើ ញីកញ៉ក់ញ៉ាំញ៉ី សរសើរបុប្ផាផលផង ។
ត្រៀងថាឲណាំថ្ងៃបង ថ្លៃអើយម្ដេចម្ដង នួនល្អងមិនមកនឹងប្ដី ។
ពាសតែបងភ្លាចសេដ្ឋី ទៅហាយប្រុសស្រី កុំអីបងនាំនាងមក ។
ឲថ្លៃប្រពៃពន្លក រៀមរើសរះរក បេះផ្កាចម្ប៉ាផ្ញើស្ងួន ។
ប្រសិនមាសមកមូលមួន បងនឹងនាំនួន បោចបេះប្រលេះផ្កាលេង ។
ឥឡូវនេះក្លូវបំបែង បងមកតែឯង ពោលទៅឲ្យនៅកំព្រា ។
ឲសមមាសមុំនា រនាំករកគ្នា ប្រាប់ទៅឃើញតែខ្មើយ ។
ទុញាប់ជួបជិតបន្តើយ មិនដែលឃ្លាតឡើយ ដោយសារទើបការផ្ទៀនថ្មី ។
ពាសតែជំពាក់សេដ្ឋី កុំរើបងស្រី មិនជាកពោលប្អូនទេណា ។
បងមកដល់នេះបេះផ្កា ថើបតាំងកន្លិដ្ឋា ចិត្តាបងទុកតាំងស្ងួន ។
ទ្រូងបងស្ទើរបែកជំបួន ទុក្ខមោព្រួយព្រួន គិតស្ងួនត្បិតស្ទាត់កន្ទង់ ។
កើតទុក្ខតុំសុខសៅហ្មង មុខមាត់ខ្ពង់ល្អង ក្រៀមក្រំផាំអស់ហើយនាង ។
ខ្លះស្រែកបន្ទូរក្អាន១ ខ្លះដៃផាន១ ខ្លះចូលជាហៃហា ១យ៉ា ។
អស់ស្រីតាសំនោរណា ក្រឡេកឃើញផ្កា ស្រែកថាពីលើដំរី ។



ស្ងួនប្រុសដែលដើរដោយដី នុះនំផ្កាអ៊ី លឿនៗក្រែងបង្កូច ។
ចម្ប៉ាប្ដផ្កាម្ចុក្រៃ ម្ដេចមិនឲ្យគេ បានមួយនឹងសៀតលេងផង ។
ប្រុសខ្លះឡើយឡាសវិធីស្ងួន មិនសូវហើយហោង យោយតាចលត្ថុំអញត្បូ ។
ស្អប់ណាស់មុខមេកំព្រយ បានតែចំឡយ ចំពាលចំពាស់តែដៃ ។
ស្មើគេខ្ញុំឯងវិស័យ ខ្លោចមេចចៃ្រ អញស្អប់មិនចង់ស្ដីផង ។
ឯភោគសេដ្ឋីជាច្បង សំណោះសាសង ខ្មើយត្នួសទៅកាន់ភរិយា ។
ស្ងួនអើយជិតហើយវិហារ ប្រហែលយល់ថា បើប្អូនមិនជំឿទៀតដល់ ។
អ្នកឯងនិងមើលខ្យល់ បក់បុប្ផាផល លំពោនទន់ទងទៅមក ។
ព្រះពាយផាត់ផាយពពក ពត្ញួនសាតមក ដង្កុំដង្គាលខ្ពលខ្មៅ ។
និន្នូនស្ងួនស្ដាប់តាវៅ សម្លេងក្រអៅ យាសយំរនិះខ្ទើយគ្នា ។
នាងថាអើណាខ្ញុំនាំ ទំនៅក្រន់ណា មេត្តាបង្ហាញខ្ញុំផង ។
សេដ្ឋីថាស្រីនួនល្អង អុញនាំក្រោយខ្នង ថ្លៃបងមកហួសមកហើយ ។
នាងនាថពិសាលគ្នាស់ខ្មើយ បពិត្រអ្នកអើយ ន៏អ្នកស្ដាប់កៃកណ្ដឹង ។
ស្រែកយាន់ទ្រហឹង ក្នុងព្រៃស្រោងស្រឹង រំពឹងគិតគូរឆ្ងល់ឆ្ងាយ ។
ខ្ញុំគួចគ្រលួចពួសាយ ខ្ញាំងពេកកម្សាយ អ្នកអើយអ្នកគិតមើលចុះ ។
សេដ្ឋីតាំងស្រីតាំងប្រុស សឹងព្រឹងព្រួលស្រួះ ប្រសាលសប្បាយតាមផ្លូវ ។
លុះតេបលេចព្រៃនោះក្ប លុះកាលវែងត្រូវ ត្រង់វត្តប្រាកដពុំឃ្លៀង ។
ស្ងួរសាយល្ហោះជ្រៃជ្រៀង ពន់ពាបទារទៀង ទន្ទឹមបំប្រះមាត់ព្រៃ ។

ដល់ស្ថានព្រះវិហារនោះហើយ ដាក់ដីរដើយ ជញ្ជូនអស់ទ្រព្យធនធាន ៗ
សេដ្ឋីឲ្យសង់រោងរាន នៅទីមួយមាន ទឹកកក់សុខសាន្តសប្បាយ ៗ
ផិតវត្តប្រាកដពុំឆ្ងាយ អស់ទុំទាំងឡាយ ប្រញាប់សង់រោងរួចរាល់ ៗ
ស្រាលស្រេចគេបបួលប្អូនថ្លៃ សេដ្ឋីអរសល់ ឲ្យជញ្ជូនអស់ទ្រព្យា ៗ
ដាក់រោងក្រោលម្ចាស់ សព្វគ្រប់ហើយណា ឡើងទៅជាសុខក្សេមក្សាន្ត ។
ដណ្តាំបាយទឹកគ្រប់ប្រាណ ដូនស្រេចលាងចាន ធូរស្បើយខ្ញុំមហាសេដ្ឋី ៗ
ហើយបបួលគ្នាប្រុសស្រី ស៊ីបាយស៊ីត្រី ឆ្អែតឆ្អល់ស្កប់ស្កល់គ្រប់ប្រាណ ៗ
ស៊ីស្លាចាំគ្នាចេញក្តាន មៀនមើលទីស្ថាន កំសាន្តសប្បាយចិត្ត ៗ
ចាស់ក្មេងដើរលេងត្រៀបត្រា មៀនមើលមេឃា ចន្ទ្រាតារាការកាយ ។
ព្រះកាយរំកើយជាត់ជាយ ជាត់ជើយក្រសាយ ត្រសុំផន្តំពាក ៗ
អប្រាត្រស្រង់ាត់សត្វជ្រក ដេកត្រៀបគ្នាមក មាត់កវិវរឡើយណា ៗ
ឯអស់ពួកពលបរិវារ វិលវិនយាត្រា នាំគ្នាចូលដេកជាសុខ ៗ
ឥតមានកេតជាទុក្ខ លង់លុះដេកលក់ ទីទៃៗគ្រប់ប្រាណ ៗ
សេដ្ឋីសោកសឹងសម្រាន្ត ជាសុខក្សេមក្សាន្ត មិនមានភារកេទហេតុអ្វី ៗ
លុះលង់ឯអន្តព្រះសុរិយ រុងរឿងរះទី ស្រទន់ពិទិសចុពា ៗ
សព្វសត្វប្រភាក់ហើរហា រះភោភោក្តា តាមគ្នាហៃៗត្រសង ៗ
សេដ្ឋីភ្ញាក់ឡើងហើយហោង ហៅអស់ទុំផង រករៀបប្រដាប់ប្រដា ៗ
...អស់ភោជ្ជក្រស្តុអាហារ ទៀនធូបលាជផ្កា ម្លូស្លាធូរគ្រឿងសុគន្ធ ៗ



ណ្តាប់សព្រាប់ការបុណ្យ ខ្លះទៅនិមន្ត យកទាំងព្រះធម្មសង្ឃ ៗ
ខ្លះយកកជរកធ្វើជ្រកង ជង់តាមលើកក្រង លើអន្តះរៀនព្រះវិហារ ៗ
ខ្លះធ្វើកាំជ្រៀបដ្ឋា ក៏ទៀនផ្កាលា តាមហោះសម្រែកសត្វសព្វ ៗ
សង់កាន់ទេពតាផងគ្រប់ ទាំងអស់កាន់ដប់ ទាំងរក្សាព្រះកាលយមរាជ ៗ
រៀបក្រងពាលីពល្វាច ស្លួរមន្តបាចសាច អញ្ជើញអស់ទាំងទេពតា ៗ
មានទាំងចំណីម្ហូបស្លា ទៀនធូបលាផ្កា ស្លាធម៌ទឹកអប់ងាក់រាន ៗ
សេដ្ឋីទៀតទាំងពីរប្រាណ ជួនជួបគ្នាបាន ធ្វើបុណ្យជាមួយផងគ្នា ៗ
ចង់ស្គាល់សួរដល់តាមា គ្រាន់បានស្គាល់គ្នា ទុកចិត្តផងឯសង្ស័យ ៗ
ទៅមកការគ្នាសព្វថ្ងៃ សួរសារប្រស្រ័យ ពីរឿងដែលមកធ្វើបុណ្យ ៗ
រំលែកចាយចែកទ្រព្យធន ប្រាថ្នាគិតគន់ រៀបរាប់ផងគ្នានោះឯង ៗ
សេដ្ឋីទាំងពីរថ្លៃថ្លង ប្រាថ្នាពិតផងក្រែង រំលែងជំនឿរួចគ្នា ៗ
ដឹងជាក់ជឿចិត្តចិន្តា ដល់សូមស៊ុំជា ក្រែងម្រាក់ហាក់ញាតិសន្តាន ៗ
ពីរពន្ធចូលក្នុងវត្តស្ថាន ធ្វើបុណ្យឲ្យបាន បាបសាបសព្វទិសទិវា ៗ
កាន់គ្រឿងសក្ការបូជា ថ្វាយព្រះជាតុមហា- បច្ចុកពោធិសត្វ ៗ
ទាំងសីលសច្ចំបរមត្ថ សូមសព្វថ្ងាត់ ប្រាថ្នាសូមបុត្រប្រុសស្រី ៗ
កាលនោះទាំងពីរសេដ្ឋី មកនឹងគ្នាគង់ ជាំរុយសំឡាញ់យើងអើយ ៗ
ប្រសិនសំណាងជាក្រោយ បានដូចចិត្តហើយ បើឯងបានកូនក្រស្រី ៗ
ហើយអញមានកូនប្រុសក្តី យើងផ្សំគ្នាអ្នី ជាប្តីប្រពន្ធស្នេហ៍ស្និទ្ធ ៗ

បើប្រុសដូចគ្នាពិត ១ ផ្សំគ្នាជាមិត្រ សូមមិត្តចូរចាំតទៅ ។
បើស្រីទាំងពីរទាក់ក្បូរ យើងនឹងកម្រូវ ផ្សំផ្សំឱ្យធ្វើជាម្រាក់ ។
៨៨- សេដ្ឋីទាំងពីរស្មោះស្ម័គ្រ ព្រួសព្រមឥតអាក់ ឥតទាក់ទើសទាល់ចិត្តា ។
លុះលន់កំឡុងទាំង ស្រេចមង្គលការ កុសលសុសសព្វឥតហ្មង ។
រីឯសេដ្ឋីទាំងសង លាគ្នាវិលផ្គន បង្គាប់អស់ទាំងបរិវារ ។
រៀបសេះរទេះគជា រីឯធនមហា- សេដ្ឋីយកប្រាក់ថ្លៃឈ្នួល ។
គិតត្រូវឱ្យទៅអ្នកជួល ទៅមកទទួល ហើយសំពះលាទៅវិញ ។
៩០- ទៅស្រុកជាសុខសួស្តី ឥតអំពល់អ្វី ជួបប្តីប្រពន្ធកូនចៅ ។
ឯសេដ្ឋីសោតក៏ទៅ បរិវារខ្ជួលខ្មៅ ហែហមអមគជសារ ។
បរចូលក្នុងព្រៃព្រឹក្សា យូរលង់តិចពក់ បានដល់គ្រឹហាទីទៃ ។
ឥតមានទុក្ខសោកភេតភ័យ សុខសប្បាយក្រៃ អស់បរិវារពលខ្ញុំ ។
អ្នកផែលនៅផ្ទះចូលជុំ ចូលមកបង្គំ សេដ្ឋីស្តីសួរសព្វសាយ ។
៩៨- ហើយលាសេដ្ឋីប្រញាយ ទៅផ្ទះរាល់កាយ ទៃ ១ និត្យនៅ ។

## បទភាកគតិ

១៩០- នេះបទកាកកាល សេដ្ឋីវិសាល រីសេសឥតសៅ
ធ្វើបុណ្យសព្វា ប្រាជ្ញាកូនចៅ កុំលង់ឡើយក្តៅ
ផលព្រះឥន្ទ្រា ។
ដូចអ្នកយកខ្លូ ភ្លើងតបកាន់ទៅ ពេលព្រះអគ្គា



ព្រះឥន្ទ្រទ្រង់ធ្វល់ ពិសាលចិន្តា ហេតុម្តេចអាសនា
អញក្តៅពេកក្តាត់
ឬមួយជាមាន អ្នកសាងសីលទាន ប្រាជ្ញាចាំសព្វ
ការសាបរេះជួន រូងថ្មើមប្រមាត់ វះវៀលក្តៀលកាត់
ដាក់ទៅជាតាន ។
ទើបទេវតាទេវិន្ទ ទេវពិចិត្តិន្ទ ទៀតទតមកថ្កាន
យល់ធនសេដ្ឋី បេតព្រោសព្រាណ ធ្វើបុណ្យចង់បាន
បុត្រីបុត្រា ។
សម្តេចកោសិន្ទ កោសិយអមរិន្ទ អមរេន្ទ្រភា
ស្តេចគុំពិកាល់ ធ្លាយធ្លល់ឡើយណា ទ្រង់ជ្រាបសព្វប្រាប់(១)-
ការគិតអនាថ ។
១៨៨- អាណិតសេដ្ឋី ទាំងពីរឃ្លាតខ្មី ខះខំសង្វាក
ជ្រាបទាំងសំណាង សាងពីបុព្វជាតិ មុនមកជាកាច
ជាគុំខ្ចិតា ។
នូវនាងទេវី សីងសាងអំពី ជាតិមុនមកណា
សូមសុំចំបុត ជាគុំខ្ញាតា តាំងចិត្តប្រាជ្ញា
ជារៀងរាល់ជាតិ ។

---
១- សម្រួលតាមសម្ពស្សកាព្យ ។

ឯកោកសេដ្ឋី ទេវកោសិយ សឹងជ្រាបដោយការពិ
គ្មាន់ព្រាងសំណាង សាងពីបុព្វជាតិ មិនមានសង្ការ
ប្រាជ្ញាខ្ពុះខ្ពស់ ។

ព្រះឥន្ទ្រគន់គិត គនាថគណិត កោកសេដ្ឋីនោះ
បានធ្វើបុណ្យបង់ បំណាន់ចំពោះ ព្រះឥន្ទ្រអនុគ្រោះ
ឲ្យដូចប្រាជ្ញា ។

កោសិយទ្រង់យស ទៀនទេសព្វស្រស ស្ងួតនិកាមា
មើលបុណ្យទេវបុត្រ នូវអស់ទេវតា ក្រែងទេវបុត្រណា
នឹងចាកច្យុត ។

១៦០– សហស្សន័យន៍នេត្រ ទ្រង់ជ្រាបដោយហេតុ យល់អង្គពង្សត្រូវ
នៅតុសិតា ស្ងួតវិសុទ្ធ ស្ដែងស្ដេចចំពុត
នឹងចុះចាកស្ថាន ។

សេតសាងសន្សំ បារមីបន្ទំ ត្រាស់ជាពុទ្ធញាណ
ព្រះឥន្ទ្រឈ្វេងយល់ គរសល់ប្រមាណ ហៀវហោះទៅឋាន
ព្រះពោធិសត្វ ។

ដល់ហើយបង្គំ ទូលអង្គប្រណម្យ ក្រុញក្រាបប្រណិប័ត
ទូលថាសូមពាន អ្នកមានបុណ្យក្លាត់ អញ្ជើញចេញថ្វាត់
ចុះចាកសួគ៌ ។



ទូលចាប់ប្រដ៏– សន្ធិគុណវៃ តាងជាកិរិយា
ធនមហាសេដ្ឋី សិរីសោភា គូស្នាងមនុស្ស
សន្សំបារមី ។

អនាគតទៅ ឯមុខនាយនៅ បានជាជិនស្រី
ចាកសង្សារវដ្ត ប្រោកជគុំបី ក្លាំងក្មេងស្មារតី
ពីសីលនិងទាន ។

១៦៨– ទេវបុត្របានស្ដាប់ ហើយហោះក្រឡាប់ ចុះចាកវិមាន
គម្រង់ត្រង់ចំ និគមក្រោមបាន ដល់ហើយចូលឋាន
ផ្ទះមហាសេដ្ឋី ។

អង្គាត្រត្រដាក់ សរនៀមសោតធ្លាក់ ដោតជាំដោយដី
បណ្ដាលអស្ចារ្យ គ្រាកាលនោះឆ្មី ទេវបុត្រពិសី
ចូលចាប់គភ៌ ។

ឯនាងទេវី ជាចមនារី រុងរឿងសោភា
លុះត្រឹកព្រាងជាក់ នាងភ្ញាក់អង្គា អង្គុយគិតថា
ហេតុស្ដេចខ្លួនអញ ។

ញីញញាច់សព្វសាច់ ដូចគល់គេថ្កច សង្កើសង្កាញ់
សង្កេតសួរគេ ក្រែងកែកចាញ់ កាលទៅគិតគ្រាញ់
ធ្វើបុណ្យសូមបុត្រ ។

អស់តាំងតាស់ខ្ញុំ ព្រហើយប្រណម្យ ក្រញាំក្រាបលំអុត
ផ្ទុបថាអ្នក វរលក្ខណ៍វិសុទ្ធ វិសេសជាមកុដ
នៃយើងកល់ក្នា ។

១៧០– ចំណាំយើងខ្ញុំ អស់តាំងតាស់ខ្ញុំ មិនថ្លូវខ្វះណា
មិនមានខពាញអ្វី អ្នកស្រីកុំថា ប្រាកដជាក់ជា
ខម្ទង់ហើយអ្នក ។

នាងឮថ្លូវហ្នះ ត្រីព្រួចពុងពោះ ត្រេកអរកេតតាក់
ក្រោកក្រែសប្រញាប់ ប្រាប់ស្វាមីភក្តិ សេដ្ឋីព្ធជាក់
អរកេតឧបមា ។

ប្រាប់ប្រាមអស់ខ្ញុំ ឲ្យមកដិតជុំ ជៀនជួយព្យាបាល
ប្រវែងប្រវៅ ដោយនូវកិច្ចការ កាលនោះឯមហា
សេដ្ឋីប្រគាន ។

ដោយបុណ្យពន្សពោ- ធិសត្វសេដ្ឋោ សពេជ្ញញាណ
បញ្ចូលក្នុងចិត្ត ឲ្យគិតធ្វើទាន ហើយសេដ្ឋីបាន
ធ្វើថ្លូវចិត្ត ។

ឲ្យខាងសព្ចថ្ងៃ គ្មានគិតសំចៃ តិចតួចឡើយណា
លុះគភ៌ទេវី នារីសោភា ទៀនទសមាសា
បរិបូណ៌ប្រពៃ ។



១៧៩– ពោធិសត្វ បានតាវវេលា កបម្ភក្សប្រពៃ
មានខ្សែលំមួយឈ្មោះ កម្មដ្ឋកកៅ ព្រោកបក់ក្នុងថ្ងៃ
បង្កិលសិរសា ។

ស្រីស្រស់ស្រគត់ ឈីឆៀបស្រយុត ស្រយង់កាយា
សេដ្ឋីក៏យកគិត ឯងឥតឧបមា ស្នាស្នុះឆ្ពេក្នា
ហៅគេហៅឯង ។

ឲ្យទៅយកខ្លួច ចូលមករហប រហង់ខ្ញុះខ្ញុន
ខ្លះចូលទៅជល់ ខចំខល់ស្ពាក់ក្ដែង តាំងពាស់តាំងក្មេង
ជ្រៀតជួយនោះទ្បោ ។

ខ្លះសោកយកថ្នាំ មកកាប់ចិញ្ច្រាំ ប្រកឆ្នាំងតាំងស្លា
ខ្លះរកថ្នាំបុក ខ្ចប់ទុកតាំងហោ ខ្លះយកតំបារ
គួសកាត់ដើងក្តក ។

ទៅក្រង់មាត់ទ្វារ គាត់គិតបន្ទារ ភ្នោចឆ្នាំងចូលជ្រែក
ត្រូវយកអំបោះ គ្រងដោះវៃផែញ្ញក វែកស្រោចស្លូតត្រង់
ព្រះទេវតាថា ។

១៨០– កំពែងវែកគាត់ សែកព្រៀពេលប់ ហើយពាំងស័មា
ប្រពាក់ប្រហែង ទ្វាចក្រែងថ្លស់ការណ៍ លង់លុះកុមារ
ប្រសូតចេញមក ។